# សៀវភៅណែនាំ
# សុវត្ថិភាពការដ្ឋានរ៉ែ



February 2017

# ការដ្ឋានវែមានសុវត្ថិភាព

# គឺការពារជីវិតរបស់លោកអ្នក






❖ កាតព្វកិច្ចអ្នកគ្រប់គ្រងសុវត្ថិភាពការដ្ឋានរ៉ែ

1. ការពារសុខភាព
2. ទប់ស្កាត់គ្រោះថ្នាក់
3. ទប់ស្កាត់ការបំពុលបរិស្ថាន
4. អភិវឌ្ឍន៍ធនធានរ៉ែ តាមបទដ្ឋានបច្ចេកទេស

# រចនាសម្ព័ន្ធសុវត្ថិភាពសម្រាប់អនុវត្តនៅការដ្ឋានរ៉ែ

ម្ចាស់អាជីវកម្ម នៅការដ្ឋានរ៉ែ ដើម្បីរក្សាបានសុវត្ថិភាព ចាំបាច់ត្រូវចាត់តាំងជ្រើសរើស អ្នកគ្រប់គ្រងសុវត្ថិភាពរួម និងបើអាចធ្វើទៅបានលើសនេះទៀត ត្រូវជ្រើសរើស អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព និងអ្នកគ្រប់គ្រងការងារ ថែមទៀត។

## រចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពនៅការដ្ឋានរ៉ែ



**អ្នកគ្រប់គ្រងសុវត្ថិភាពរួម**

**អ្នកគ្រប់គ្រងបច្ចេកទេសសុវត្ថិភាព**

**បុគ្គលិកបច្ចេកទេសសុវត្ថិភាព**

(អ្នកទទួលបន្ទុកបំផ្ទុះនិងសុវត្ថិភាពក្រៅរូង
អ្នកទទួលបន្ទុកផ្នែកអគ្គិសនី
អ្នកទទួលបន្ទុកផ្នែកគ្រឿងចក្រ ។ល។)

# ការងារទាំងនេះត្រូវមានសញ្ញប័ត្រនិងការអប់រំ ជាមុនសិន

ក្នុងករណីអនុវត្តការងារទាំងនេះ  គឺត្រូវការរៀនសូត្រដើម្បីប្រលងយកសញ្ញាប័ត្រនិងទទួលការបណ្តុះបណ្តាលផ្នែកសុវត្ថិភាព។





បច្ចេកទេសបើកបរ Excavator និង Bulldozer



ការបើកបររថយន្តដឹករ៉ែប្រភេទធុនធ្ងន់ (Dump truck)




ការងារជំនាញផ្នែកបំផ្ទុះថ្ម

ចំពោះបន្ទប់សំរាកឬការិយាល័យរបស់ការដ្ឋានរ៉ែ ត្រូវសរសេរបិតបង្ហាញពី 「បទបញ្ជាឬសេចក្តីប្រកាសផ្សេងៗដែលកម្មកររ៉ែត្រូវគោរព」 ។



## ការអប់រំចំពោះកម្មករធ្វើការនៅទីកន្លែងមានធូលីហុយ

ចាំបាច់ត្រូវមានការបណ្តុះបណ្តាលពីសុវត្ថិភាពទាក់ទងនឹងធូលីហុយដល់កម្មកររ៉ែនៅទីកន្លែងធ្វើការងារមានធូលីហុយខ្លាំង។



## I. កន្លែងជីកយកថ្មរ៉ែនៅការដ្ឋានរ៉ែបើក

## 1. អ្នកគ្រប់គ្រងត្រូវដើរល្បាតមើលសុវត្ថិភាពនៅការដ្ឋានរ៉ែ





រាយការណ៍ទៅម្ចាស់ក្រុមហ៊ុន




លើកស្លាកសញ្ញានៅកន្លែងមានគ្រោះថ្នាក់

## 2.ការទប់ស្កាត់ការបាក់ធ្លាក់

ដើម្បីទប់ស្កាត់ ការបាក់ រលំផ្ទាំងថ្ម ត្រូវរក្សាជំរាលមុំសុវត្ថិភាព ឲ្យបានសមស្របដោយ តម្រូវឲ្យ កាំ ថ្នាក់នីមួយៗ មានកំពស់សុវត្ថិភាពសមរម្យ។




## 3. ការត្រួតពិនិត្យ

មុននឹងធ្វើការងារ ត្រូវត្រួតពិនិត្យអំពីថ្មប្រេះ (Loose Rock) ជាមុនសិនករណីមានថ្មបែបនេះ ត្រូវយកថ្មនោះចេញតាមវិធីមានសុវត្ថិភាពជាមុនសិន ។



## 4. ហាមធ្វើការងារ លើក្រោម នៅពេលតំណាលគ្នា វាអាចមានគ្រោះថ្នាក់ខ្លាំង




## 5. ការទប់ស្កាត់រអិលធ្លាក់

① ទីកន្លែងទំលាក់ថ្ម ត្រូវប្រើកំណល់មានភាពមាំសម្រាប់កល់កង់ក្រោយ ដើម្បីជៀសវាងរថយន្តរអិលធ្លាក់ធ្លាក់។



② នៅពេលរុញថ្មឬពំនូកដី ទំលាក់ទៅក្នុងចំណោត ត្រូវយកថ្មឬពំនូកដី មួយពំនូកផ្សេងទៀត យកមករុញ ដើម្បីទប់ស្កាត់ការជ្រុលធ្លាក់គ្រឿងចក្រ។



## 6.ការទប់ស្កាត់ការរអិលធ្លាក់

ពេលធ្វើការនៅទីកន្លែងមានគ្រោះថ្នាក់ឬរអិលត្រូវប្រើជន្ទល់សុវត្ថិភាពហើយអ្នកធ្វើការងារនោះត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព។



## 7. **ការផ្អាកការងារនៅពេលអាចនឹងមានគ្រោះថ្នាក់**

នៅពេលអាចនឹងមានគ្រោះថ្នាក់ តាមរយៈរន្ទះភ្លៀង។ល។ សូមផ្អាកការងារ និងភៀសខ្លួនទៅរកកន្លែងមានសុវត្ថិភាព។



## II . ចំនុចប្រយ័ត្នចំពោះរថយន្តនិងគ្រឿងចក្រនៅការដ្ឋានរ៉ែ

### 1. កាតព្វកិច្ចក្នុងការបើកបរសម្រាប់អោយមានសុវត្ថិភាព

① ហាមផ្ទុកលើសចំណុះ





② ហាមប្រើគ្រឿងចក្រខុសពីមុខងាររបស់វា

③ ហាមប្រើគ្រឿងចក្រខុសគោលដៅ (សម្រាប់ជីកឬកាយ)






④ ហាមជិះ ក្រៅពីចំនួនកៅអីមានកំណត់



⑤ ហាមចូលដោយគ្មានការប្រុងប្រយ័ត្ន នៅពេលយានយន្ត ឬគ្រឿងចក្រកំពុងដំណើរការ

2. វិធានការ នៅពេលធ្វើការត្រួតពិនិត្យ




នៅពេលជួសជុលក្រោមប៉ែល ត្រូវមានជន្ទល់ទ្រត្រឹមត្រូវជាមុនសិន

3. ផ្លូវកោងនៅក្នុងការដ្ឋានត្រូវមានស្លាកសញ្ញា



4. វិធានការចំពោះករណីមុនឃ្លាតចេញពីគ្រឿងចក្រ




- ហាមជក់បារី នៅក្បែរប្រេងឥន្ធនៈ
- ពន្លត់ម៉ាស៊ីន ពេលចាក់ប្រេង

## III. សម្ភារប្រើប្រាស់សម្រាប់ធ្វើការបំផ្ទុះ

**1.** ប្រយ័ត្នចំពោះចំនុចនៃការប្រើប្រាស់ប្រភេទរំសេវនិងការបំផ្ទុះ

ដើម្បីទប់ស្កាត់ការប៉ះកកិតនៅពេលញាត់រំសេវត្រូវប្រើសម្ភារដូចខាងក្រោម៖

ហាមប្រើដែកឬលោហៈបុកផ្នុក(Stemming)







① ត្រូវប្រើទុយោរមិនផ្ទុកចរន្ត

② ប្រើខ្សែម៉ាស់តភ្ជាប់ទៅក្នុងដី

③ ត្រូវប្រុងប្រយ័ត្ននៅពេលញាត់




## 2. វិធានការ នៅពេលធ្វើការបំផ្ទុះ

នៅពេលធ្វើការបំផ្ទុះត្រូវចាត់វិធានការដូចខាងក្រោម៖

① ដាក់មនុស្សយាមមើល ⟶ ផ្លូវសំខាន់ៗ

② លើកស្លាកសញ្ញាប្រយ័ត្ន ⟶ នៅផ្លូវផ្សេងទៀត

③ ប្រយ័ត្នចំពោះទីកន្លែងធ្វើការបំផ្ទុះ⟶អ្នកធ្វើការផ្សេងទៀតនៅក្បែរតំបន់ធ្វើការបំផ្ទុះ



## 3. ការទប់ស្កាត់គ្រោះថ្នាក់តាមរយៈការបំផ្ទុះ

ដើម្បីទប់ស្កាត់គ្រោះថ្នាក់របស់ថ្មផ្លោងទៅខាងក្រៅការដ្ឋានត្រូវគោរពតាមចំនុចដូចខាងក្រោម៖

① ដាក់បរិមាណរំសេវតាមលក្ខណៈបច្ចេកទេស

② តំឡើងបរិក្ខារទប់ស្កាត់ការពារ ឬកំណត់តំបន់ហាមមិនអោយមនុស្សចូល(ដាក់អ្នកយាម ឬតម្លើងស្លាកសញ្ញា)



## IV. ចំនុចប្រយ័ត្ននៅពេលប្រើប្រាស់ភ្លើងនៅការដ្ឋានរ៉ែបើក

**1.** បរិក្ខារពន្លត់អគ្គីភ័យនៅក្នុងអគារនៃការដ្ឋានរ៉ែបើក

ចំពោះបរិក្ខារពន្លត់អគ្គីភ័យ ត្រូវដាក់នៅកន្លែងងាយយកមកប្រើប្រាស់



**2.** ការកំហិតក្នុងការប្រើភ្លើង

នៅពេលធ្វើការផ្សារឬកាត់ដែក ត្រូវមានបរិក្ខារពន្លត់អគ្គីភ័យ នៅក្បែរអ្នកផ្សារ។




**3.** ចំពោះក្រណាត់ឬក្រដាសងាយឆេះ ត្រូវដាក់ក្នុងធុងដែក

ក្រណាត់ជូតដែលមានជាតិប្រេងឬខ្លាញ់ ត្រូវដាក់ក្នុងធុងដែកគ្របឲ្យជិត។



4.ទីកន្លែងប្រើប្រាស់ភ្លើង

អ្នកបានប្រើប្រាស់ភ្លើង ត្រូវពន្លត់ឲ្យបានច្បាស់លាស់។



## V. ចំនុចប្រយ័ត្នក្នុងការប្រើបរិក្ខារអគ្គិសនី

ទប់ស្កាត់ការឆក់ចរន្តអគ្គិសនី

(1) ត្រូវបិទកុងតាក់ និងចាក់សោរ

(2) ត្រូវផ្តល់ព័ត៌មានអំឡុងពេលជួសជុល ត្រូវបិទកុងតាក់សិន



## VI. ការទប់ស្កាត់ធូលីហុយ នៅការដ្ឋានរ៉ែបើក

1. ទប់ស្កាត់ធូលីហុយ

ត្រូវមានបំពាក់ប្រព័ន្ធបាញ់ទឹកនៅផ្នែកខ្សែសង្វាក់ផលិតកម្មដែលជាប្រភពបញ្ចេញធូលីហើយ ចាំបាច់ត្រូវពាក់ម៉ាស់។



2. ប្រើប្រាស់រថយន្តស្រោចទឹក ដើម្បីកាត់បន្ថយការហុយធូលី នៅការដ្ឋានរ៉ែ



3. ការប្រើប្រាស់ម៉ាស៊ីនខ្យល់

ចំពោះវ៉ាន នាឡិកាសំពាធ នាឡិកាកំដៅ វ៉ានសុវត្ថិភាព បំពង់ខ្យល់ របស់ម៉ាស៊ីនខ្យល់ ត្រូវសំអាតជាប្រចាំ។



4. ការទប់ស្កាត់គ្រោះថ្នាក់



5. នៅពេលឆាបឬសំលៀងដែក ត្រូវមានសម្លៀកបំពាក់និងបរិក្ខារសុវត្ថិភាព ត្រូវប្រើ មួក វ៉ែនតា ស្រោមដៃ ម៉ាស់ ស្បែកជើងសុវត្ថិភាពនិងកាសត្រចៀក។



6. វិធានការនៅពេលជួសជុលម៉ាស៊ីន



7. ជណ្តើរនិងបង្កាន់ដៃសុវត្ថិភាព



៨. ផ្លូវដើរសុវត្ថិភាព



9. ធ្វើការនៅទីខ្ពស់ត្រូវមានខ្សែក្រវ៉ាត់សុវត្ថិភាព



## VII. វិធានការទប់ស្កាត់ការបំពុលបរិស្ថាន

① ត្រូវបាញ់ទឹកសម្អាតជាប្រចាំនៅច្រកចេញចូលការដ្ឋានរ៉ែ



② ហាមបញ្ចេញទឹកកខ្វក់ទៅក្រៅការដ្ឋាន




③ ហាមចោលកាកសំណល់នៅទីកន្លែងសាធារណៈ



④ ហាមទុកកាកសំណល់ហៀរចេញក្រៅការដ្ឋានរ៉ែ



Edited by Working Team members of GDMR

1. Mr. HONG Bona
2. Mr. KONG Sitha
3. Mr. LAI Zanith
4. Mr. TY Pisethcheat
5. Mr. IM Sim
6. Mr. YIN Ratanak
7. Mr. SOU Phires

Japan International Cooperation Agency (JICA)

Ministry of Mines and Energy
General Department of Mineral Resources
in the Kingdom of Cambodia

This textbook is free